ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.

ឱកាសការងារ

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ទទួលបានអាជ្ញាប័ណ្ណផ្សារការពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៥ និងបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ដោយសម្រេចបាននូវភាពជោគជ័យ និង ការរីកចម្រើន យ៉ាងឆាប់រហ័ស។ ជាក់ស្តែង **ហ្វូតាបា** បានពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនជាបន្តបន្ទាប់ ដោយបានដាក់ ឱ្យដំណើរការ ការិយាល័យសាខាថ្មីបន្ថែមចំនួនបួន (៤) បន្ថែមទៀត រួមមានរាជធានីភ្នំពេញចំនួនពីរសាខា (២) សាខាក្រុង ច្បារមនចំនួនមួយ (១) និងសាខាក្រុងដូនកែវ ចំនួនមួយ (១) ដែលជាសាខាថ្មីចាប់បើកដំណើរការនៅក្នុងខែមីនា ឆ្នាំ ២០២៣។ បច្ចុប្បន្ន **ហ្វូតាបា** ត្រូវការជ្រើសរើសបុគ្គលិក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបម្រើការងារក្នុងមុខ តំណែងដូចខាងក្រោម ៖

មុខតំណែង	ចំនួនជ្រើសរើស	ទីតាំង	ប្រាក់ឈៀវត្ស
មន្ត្រីឥណទាន	០២នាក់	សាខាក្រុងដូនកែវ	ចរចា

កាតព្វកិច្ច និងការទទួលខុសត្រូវ

- ផ្សព្វផ្សាយផលិតផល និងសេវាកម្មរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ទៅដល់អតិថិជនសក្តានុពល។
- ធ្វើការសិក្សា វិភាគ វាយតម្លៃលទ្ធភាពសង និងទ្រព្យដាក់ធានារបស់អតិថិជនឱ្យបានត្រឹមត្រូវ។
- រៀបចំរបាយការណ៍ និងសំណើសុំឥណទាន ដើម្បីដាក់ជូននាយកសាខាឬគណៈកម្មាធិការឥណទានពិនិត្យ និងអនុម័ត
- ថែរក្សាទំនាក់ទំនងល្អ ជាមួយអតិថិជនដែលមានស្រាប់ និងស្វែងរក អតិថិជនថ្មីបន្ថែម។
- បញ្ចេញឥណទានទៅតាមផែនការ ដែលបានកំណត់ដោយនាយកសាខា។
- ពង្រឹងគុណភាពនៃការប្រមូល និងដោះស្រាយបញ្ហាយឺតយ៉ាវក្នុងការសងត្រឡប់ឥណទានមកវិញឱ្យបានទាន់ពេល។
- បង្កើនទំនាក់ទំនងជាមួយអាជ្ញាធរក្នុងតំបន់ ដែល គ្រឹះស្ថាន **ហ្វូតាបា** កំពុងធ្វើប្រតិបត្តិការ និងសិក្សាអំពីគូប្រកួតប្រជែងក្នុងតំបន់ ព្រមទាំងរៀបចំផែនការ ដើម្បីទទួលបានចំណែកទីផ្សារបន្ថែម។
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ ជូនអ្នកគ្រប់គ្រង។

លក្ខខណ្ឌជ្រើសរើស

- បញ្ចប់ថ្នាក់ទី១២ ឬជានិស្សិតកំពុងបន្តការសិក្សា។
- មានជំនាញក្នុងការដោះស្រាយបញ្ហា។
- មានចំណេះជំនាញទាក់ទងនឹងឥណទាន។
- មានភាពស្មោះត្រង់ និងអាចធ្វើការងារជាក្រុម។
- មានទំនាក់ទំនងល្អ និងរហ័សរហួន។
- មានម៉ូតូប្រើប្រាស់ផ្ទាល់ខ្លួន។

ផ្ទះលេខ៤៧ មហាវិថីយោធពលខេមរភូមិន្ទ ភូមិ១ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ.
N° 47, Yothapol Khemarak Phoumin Blvd., Phum 1, Sangkat Tuol Tumpung Ti Pir, Khan Chamkar Mon, Phnom Penh.
info@futabamfi.com.kh www.futabamfi.com.kh Futaba Microfinance Plc. Hot Line : 070 312 333

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផ្តល់ជូនបុគ្គលិកពេញសិទ្ធិនូវ អត្ថប្រយោជន៍ផ្សេងៗដូចជា៖

១. ផ្តល់ប្រាក់បៀវត្សប្រកួតប្រជែងទៅតាមបទពិសោធន៍។ ២. ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ ១០០% នៃប្រាក់បៀវត្ស។ ៣. ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ ១០០% នៃប្រាក់បៀវត្ស។ ៤. ការធានារ៉ាប់រងសុខភាពដល់បុគ្គលិក និងសមាជិកគ្រួសារ (ប្តី/ប្រពន្ធ និងកូន២នាក់)។ ៥. ការធានារ៉ាប់រងគ្រោះថ្នាក់ដល់ជីវិត ២៤ ម៉ោង។ ៦. ប្រាក់ឧបត្ថម្ភចំណងដៃ អាពាហ៍ពិពាហ៍បុគ្គលិក។ ៧. ផ្តល់ប្រាក់កម្ចីដល់បុគ្គលិកក្នុងអត្រាការប្រាក់សមរម្យ។	៨. ការឈប់សម្រាកអនុលោមតាមច្បាប់ក្រសួងការងារ និងការឈប់សម្រាកប្រចាំឆ្នាំ។ ៩. ផ្តល់ឯកសណ្ឋានការងារ។ ១០. ផ្តល់ស៊ីមកាត និងឈ្នួលទូរសព្ទដៃ។ ១១. ប្រាក់ឈ្នួលម៉ូតូ $៨០ ក្នុង១ខែ សម្រាប់មន្ត្រីឥណទាន។ ១២. ប្រាក់រង្វាន់លើកទឹកចិត្ត ទៅមន្ត្រីឥណទានដែលសម្រេចបានគ្រប់ផែនការ *(Incentive)*។ ១៣. ប្រាក់ឧបត្ថម្ភ និងសម្ភារៈប្រើប្រាស់ផ្សេងៗ តាមគោលការណ៍កំណត់របស់គ្រឹះស្ថាន **ហ្វូតាបា**។

- **<u>របៀបដាក់ពាក្យ</u>៖** បេក្ខជន / បេក្ខនារី ដែលមានចំណាប់អារម្មណ៍បំពេញការងារជាមួយ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមផ្ញើពាក្យសុំបម្រើការងារ **(CV និង Cover Letter)** ជាមួយរូបថត **(4x6)** ដោយបញ្ជាក់ពីមុខតំណែង និងទីតាំងដែលចង់បម្រើការងារឱ្យបានច្បាស់លាស់ និងយកមកដាក់នៅតាមការិយាល័យសាខារបស់ **ហ្វូតាបា** ឬ អាចផ្ញើមកតាមរយៈ Email: Recruitment@futabamfi.com.kh (នាយកដ្ឋានធនធានមនុស្ស)។
- **<u>ឈប់ទទួលពាក្យត្រឹម</u>៖** ***<u>ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៦ ម៉ោង០៥:០០ល្ងាច</u>*** *(អ្នកដាក់ពាក្យមុនត្រូវបានលើកទឹកចិត្ត)*
- **<u>សម្រាប់ព័ត៌មានបន្ថែម</u>៖**

  សូមទំនាក់ទំនងផ្នែកធនធានមនុស្ស ទូរសព្ទលេខ: **070 479 333** ឬចូលទៅកាន់គេហទំព័រ www.futabamfi.com.kh ឬ Facebook **Futaba Microfinance Plc.**

(បេក្ខជនជានារី និងជនមានពិការភាពត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យបម្រើការងារ)